**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...០៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ២៦៦ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១០០៧ អនក្រ.តត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- បានឃើញអនុក្រឹត្យលេខ ២៦៦ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រាមួយ .-**

មាត្រា១ នៃអនុក្រឹត្យលេខ ២៦៦ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ត្រូវបានធ្វើការកែសម្រួល ដូចតទៅ៖

**មាត្រា១ _ ថ្មី**

ត្រូវបានបង្កើត **"គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់"** ដែលហៅកាត់ថា **"គ.ប.ច."** ស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌។

**គ.ប.ច.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ** | | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** | | អនុប្រធាន |
| ៤- ឯកឧត្តមបណ្ឌិត **ឆាយ ហុកផេង** | | អនុប្រធាន |
| ៥- លោក **សូ មុយឃៀង** | | សមាជិក |
| ៦- លោក **ស៊ឹង ផុស** | | សមាជិក |
| ៧- ឯកឧត្តម **ឃាង សេង** | | សមាជិក |
| ៨- ឯកឧត្តម **ស៊ា ម៉ៅ** | | សមាជិក |
| ៩- លោកជំទាវ **ខៀវ សុផានី** | | សមាជិក |
| ១០-ឯកឧត្តម **នាក់ សើគីរីន** | | សមាជិក |
| ១១-ឯកឧត្តម **សន សោភ័ណ** | | សមាជិក |
| ១២-ឯកឧត្តម **ចាយ ច័ន្ទតារាវណ្ណ** | | សមាជិក |
| ១៣-ឯកឧត្តម **អ៊ូច ចាន់ណូរ៉ា** | | សមាជិក |
| ១៤-ឯកឧត្តម **តាន់ហ៊ាង ដាវ័ណ្ណ** | | សមាជិក |
| ១៥-ឯកឧត្តម **បែន វិស្ណុ** | | សមាជិក |
| ១៦-ឯកឧត្តម **មូសារ អ៊ីស្សាម** | | សមាជិក |
| ១៧-ឯកឧត្តម **ឃ្លោក ដារ៉ា** | | សមាជិក |
| ១៨-លោកបណ្ឌិត **យ៉ាន់ វ៉ាន់ដឹលុច** | | សមាជិក |
| ១៩-លោក **ហ៊ីង គីមថន** | | សមាជិក |
| ២០-កញ្ញា **ហេ ផល្លាសម្បត្តិ** | | សមាជិក |
| ២១-លោក **អែម ឧត្តម** | | សមាជិក |
| ២២-លោក **ផង់ ភិរុណ** | | សមាជិក។ |

**គ.ប.ច.** អាចមានសមាសភាពបន្ថែមផ្សេងទៀត ដែលត្រូវជ្រើសរើសចេញពីក្នុងចំណោមឥស្សរជន ឬមន្ត្រីរាជការ ដែលមានចំណេះដឹង និងបទពិសោធន៍ការងារក្នុងវិស័យនីតិសាស្ត្រ រដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬអក្សរសាស្ត្រ និងត្រូវតែងតាំងដោយអនុក្រឹត្យដោយឡែកតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់បញ្ជូនតំណាងទៅតាមសេចក្ដីស្នើសុំរបស់ **គ.ប.ច.**។

អនុប្រធាន និងសមាជិក **គ.ប.ច.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ប.ច.**។ ប្រធាន **គ.ប.ច.** អាចចាត់តាំងអនុប្រធានជាតំណាងដើម្បីដឹកនាំកិច្ចប្រជុំ **គ.ប.ច.** ឬបំពេញភារកិច្ចផ្សេងទៀត។

**មាត្រាពីរ**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ